ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ១៧៤ ក៣ហ

# កំណត់ហេតុ

ថ្ងៃអង្គារ បួនរោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីពីរ ខែតុលា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងពីរនិងសាមសិបនាទីរសៀល នៅសាលប្រជុំខេត្តរតនគិរី ទីស្តីការក្រសួងមហាផ្ទៃ បានបើកកិច្ចប្រជុំ ដើម្បីបន្តពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុច ចាន់ណូរ៉ា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ។**

សមាសភាពអញ្ជើញចូលរួម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ី សុខឃី | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ម៉ាន រ៉ាស៊ី | អនុប្រធានក្រុមប្រឹក្សានីតិកម្ម |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ស្វាយ ចាន់ដា | អគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានមនុស្ស |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ឹម ប្រណិតា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៥-ឯកឧត្តម | ស៊ី ខរិន | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | សំ ប៊ូរ | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៧-ឯកឧត្តម | សុខ លីនណា | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៨-ឯកឧត្តម ឧត្តមសេនីយ៍ទោ | សាខ សុធន | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ |
| ៩-លោកជំទាវ ឧត្តមសេនីយ៍ទោ | រ៉ែន សិរីលក្ខណា | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| ១០-ឯកឧត្តម ឧត្តមសេនីយ៍ឯក | សិទ្ធ ម៉ុនធី | អនុប្រធានសេនាធិការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១១-លោក ឧត្តមសេនីយ៍ត្រី | ខេង ម៉ូលីដា | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន |
| ១២-លោក ឧត្តមសេនីយ៍ត្រី | ឈឹម សម្បត្តិ | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៣-លោក | ទង វីឫទ្ធិ | សមាជិក នៃក្រុមប្រឹក្សានីតិកម្ម |
| ១៤-លោក វរសេនីយ៍ឯក | ឱម ទិត្យសត្យា | សមាជិក នៃក្រុមប្រឹក្សានីតិកម្ម |
| ១៥-លោកស្រី | ព្រុំ សួនសត្យា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន |
| ១៦-លោក វរសេនីយ៍ត្រី | ជុន ស៊ីនលី | នាយផ្នែក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៧-លោក វរសេនីយ៍ទោ | សេក ឡង់ឌី | អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ និងជាលេខាកត់ត្រា |
| ១៨-លោក អនុសេនីយ៍ឯក | ហុង គិចឈៀង | នាយផ្នែក នៃនាយកដ្ឋានសរុបនិងស្ថិតិ និងជាលេខាកត់ត្រា |

ប៉ុន្តែត្រង់ចំណុចទាំងពីរខាងលើនេះ អង្គប្រជុំពុំទាន់សម្រេចយ៉ាងណានៅឡើយទេ ដោយដាក់ហែឡាយពណ៌លឿងរក្សាទុកសិន។

-**មាត្រា៦** ចំណុចទី២ អង្គប្រជុំបានឯកភាពគ្នាលើខ្លឹមសារនេះទាំងស្រុង។

-**មាត្រា៦** ចំណុចទី៣ អង្គប្រជុំបានឯកភាពគ្នាលើខ្លឹមសារនេះទាំងស្រុង។

ក្រោយពីបានឆ្លងមតិយោបល់ វែកញែកគ្នាយ៉ាងផុសផុល ពិនិត្យ ពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់រួចមក **ឯកឧត្តម ប្រធានអង្គប្រជុំ** បានដាក់ចេញនូវគោលការណ៍ និងសំណូមពរ រួមមាន ដូចខាងក្រោម ៖

១- ស្នើឱ្យមន្ត្រីជំនាញ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ជួយបកប្រែអត្ថបទភាសាអង់គ្លេសនៃសេចក្តីព្រាងនេះ ចំពោះចំណុចមាត្រាដែលអង្គប្រជុំមិនទាន់បានពិភាក្សា ឱ្យទៅជាភាសាខ្មែរ សម្រាប់ដាក់ជូនអង្គប្រជុំនៅកិច្ចប្រជុំបន្ទាប់ ដើម្បីងាយស្រួលយល់ពីខ្លឹមសារ និងគោលបំណងច្បាស់លាស់តាមមាត្រានីមួយៗ នៃសេចក្តីព្រាងអនុស្សរណៈនេះ។

២-នៅពេលក្រុមការងារពិនិត្យ និងកែសម្រួលរួចហើយ ក្រុមការងារបច្ចេកទេសដែលមានតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ គួររៀបចំឱ្យមានជំនួបពិភាក្សាជាមួយភាគីសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ាមួយជំហានសិន ដើម្បីចង់ដឹងពីគោលជំហរ និងគោលបំណងផ្ទាល់របស់គាត់ ថាតើគាត់ចង់បានតម្រូវការដាក់លាក់អ្វីខ្លះដែលត្រូវចែងក្នុងសេចក្តីព្រាងនេះ មុននឹងឈានដល់ការចុះហត្ថលេខាលើ MOU។

៣-ចំពោះមាត្រាដែលនៅសេសសល់ចាប់ពីមាត្រា៧តទៅ អង្គប្រជុំនឹងរៀបចំដាក់កម្មវិធីប្រជុំឆ្លងមតិយោបល់ ពិនិត្យ ពិភាក្សា នៅសប្តាហ៍ក្រោយបន្តទៀត។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងប្រាំល្ងាច នាថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១១ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

**លេខាកត់ត្រា**

វរសេនីយ៍ទោ **សេក ឡុងឌី**

**បានឃើញ និងឯកភាព**

ថ្ងៃ១ ៣៨ ១២ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១១ខែតុលា ឆ្នាំ២០២៣

**ប្រធានអង្គប្រជុំ**

**អ៊ុច ចាន់រស្មី**